ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 01 / 2016
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥

## សវនាការលើភស្តុតាង - ថ្ងៃ ៣៥០

រៀបចំដោយ៖ **ជា ស៊ីវហ៉ង** និង Evelyn CAMPOS SANCHEZ

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Martin KAROPKIN |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៉ង , កញ្ញា Evelyn CAMPOS SANCHEZ |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicholas KOUMJIAN, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី |

| |
|---|
| សាក្សី៖ (2-TCW-1000) |
| មេធាវីប្រឹក្សា៖ លោក មឿន សុវណ្ណ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ិច អរុណ |
| ផ្សេងៗ៖ លោកស្រី សំ មករា, លោក ឡូញ ង៉ែត, កញ្ញា ណី សុមេត្តា, លោក នូ មនោរ័ត្ន, កញ្ញា ស្រី ណាក់, កញ្ញា Elena FAVARO VIANA |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០៨ | បញ្ចប់ម៉ោង៖ ១៤.៤២ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១២ | បញ្ចប់ម៉ោង៖ ១០.៣៣ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣២ | បញ្ចប់ម៉ោង៖ ១៣.៣២ |
| សម្រាកពេលរសៀល | គ្មាន | គ្មាន |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ១៥ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៩ | ០៩.១១ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.១១ | ០៩.១២ |
| សំណើរបស់មេធាវីការពារក្ដី នួន ជា អំពីភាពស្រដៀងគ្នារវាងសាក្សី ប្រាក់ ខឿន (2-TCCP-300) និងសាក្សីនៅក្នុងឯកសារ E3/4732 | មេធាវីការពារក្ដី នួន ជា<br><br><br><br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខ | ០៩.១២<br>០៩.២២<br>០៩.២៥<br>០៩.២៨<br>០៩.១៩<br>០៩.២០<br>០៩.២៣<br>០៩.២៩ | ០៩.១៩<br>០៩.២៣<br>០៩.២៧<br>០៩.២៩<br>០៩.២០<br>០៩.២៥<br>០៩.២៥<br>០៩.៣០ |

| | | | |
|---|---|---|---|
| ការតាំងសំណួរទៅកាន់សាក្សី (2-TCW-1000) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>អង្គជំនុំជម្រះ | ០៩.៣០<br>០៩.៤៣<br>១៣.៣៧<br>១៣.៥៤ | ០៩.៤៣<br>១៣.៣៧<br>១៣.៥៤<br>១៤.៣៦ |
| ការបញ្ជាក់របស់សហព្រះរាជអាជ្ញាអំពីការមិនជំទាស់ទៅនឹងការស្តាប់សក្ខីកម្មរបស់លោក Robert Lemkin នៅក្នុងសំណុំរឿង ០០២/០២ | សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ១៤.៣៧<br>១៤.៣៨ | ១៤.៣៨<br>១៤.៣៨ |
| ការបញ្ជាក់របស់សហព្រះរាជអាជ្ញាអំពីការផ្ញើរសារអេឡិចត្រូនិចនូវបញ្ជីឈ្មោះសាក្សីបន្ថែមសម្រាប់អង្គហេតុការប្រព្រឹត្តលើជនជាតិវៀតណាម | សហព្រះរាជអាជ្ញា | ១៤.៣៩ | ១៤.៣៩ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>សំណើរបស់មេធាវីការពារក្តី នួន ជា អំពីភាពស្រដៀងគ្នារវាងសាក្សី ប្រាក់ ឌឿន (2-TCCP-300) និងសាក្សីដែលមានឈ្មោះនៅក្នុងឯកសារ E3/4732</u>**

មេធាវីការពារក្តី នួន ជា បានធ្វើសេចក្តីសន្និដ្ឋានដោយផ្អែកលើដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន (2-TCCP-300) ដែលបានមកផ្តល់សក្ខីកម្មកាលពីថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥។ មេធាវីការពារក្តីបានស្នើឱ្យសហមេធាវីនាំមុខបង្ហាញព័ត៌មានអំពីថាតើ ប្រាក់ ឌឿន គឺជាមនុស្សតែមួយដែលត្រូវបានយោងនៅក្នុងឯកសារ E3/4732 ឬយ៉ាងណា ដែលត្រូវបានចោទថាបានសម្លាប់ប្រពន្ធវៀតណាមរបស់

ខ្លួន ដែលផ្ទុយពីសក្ខីកម្មរបស់គាត់។ មេធាវីការពារក្ដីបានលើកឡើងថា ការបញ្ជាក់នេះអាចឱ្យមេធាវីការពារក្ដីសម្រេចបានថាតើ ត្រូវស្នើសុំកោះហៅសាក្សី ប្រាក់ ឌឿន មកវិញឬយ៉ាងណា។ មេធាវីនាំមុខបានឆ្លើយតបថា មេធាវីការពារក្ដី នួន ជា មិនមានសំអាងច្បាប់នោះទេ លើកលែងតែសំណើរបស់មេធាវីការពារក្ដីដាក់ ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ មេធាវីនាំមុខ បានបញ្ជាក់ថាបុគ្គលដែលត្រូវបានយោងនៅក្នុងឯកសារ E3/4732 មិនមែន ប្រាក់ ឌឿន នោះទេ។ មេធាវីនាំមុខបញ្ជាក់បន្ថែមថាខ្លួននឹងឆ្លើយតបទៅនឹងសំណើជាផ្លូវការ ជាលាយលក្ខណ៍អក្សររបស់មេធាវីការពារក្ដី នួន ជា ប៉ុណ្ណោះ ឬ សម្រេចតាមអង្គជំនុំជម្រះ។

**<u>ការតាំងសំណួរទៅកាន់សាក្សី (2-TCW-1000)</u>**

អង្គជំនុំជម្រះ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ បានតាំងសំណួរទៅកានសាក្សី 2-TCW-1000។ វិធានការការពារដែលមាននៅក្នុងឯកសារ E319/3 ចូលជាធរមាន។

**<u>ការជំទាស់របស់មេធាវីការពារក្ដី នួន ជា ទៅនឹងការដាក់ឯកសារ E3/928 និង E3/929 ក្នុងការសួរដេញដោលសាក្សី</u>**

មេធាវីការពារក្ដី នួន ជា បានជំទាស់ទៅនឹងការដាក់ឯកសារ E3/928 និង E3/929 ក្នុងការសួរដេញដោលសាក្សី។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថាឯកសារទាំងពីរនេះគឺជាឯកសារតែមួយដែលមានការបកប្រែផ្សេងគ្នា។ មេធាវីការពារក្ដី ខៀវ សំផន ក៏បានជំទាស់ផងដែរ និងបានលើកឡើងថានីតិវិធីក្នុងការដាក់ឯកសារ និងការសួរដេញដោលសាក្សីនៅក្នុងសវនាការ មិនត្រូវបានអនុវត្តតាមនោះទេ។ មេធាវីនាំមុខបានលើកឡើងថា ឯកសារនេះត្រូវបានដាក់ចំពោះមុខសាក្សីរួចទៅហើយជាឯកសារ E319/23.3.44.3 (E3/928) ដែលឯកសារដែលបានដាក់នេះជាឯកសារភ្ជាប់។ អង្គជំនុំជម្រះបដិសេធការជំទាស់ និងបានសម្រេចថាឯកសារ និងព័ត៌មានពីសាក្សីគឺមានភាពពាក់ព័ន្ធគ្នា។

**<u>ការបញ្ជាក់របស់សហព្រះរាជអាជ្ញាអំពីការមិនជំទាស់ទៅនឹងការស្ដាប់សក្ខីកម្ម របស់លោក Robert Lemkin នៅក្នុងសំណុំរឿង ០០២/០២</u>**

សហព្រះរាជអាជ្ញាបានបញ្ជាក់ថាខ្លួនមិនជំទាស់ទៅនឹងការស្ដាប់សក្ខីកម្មរបស់លោក Robert Lemkin នៅក្នុងសវនាការសំណុំរឿង ០០២/០២ ឡើយ។

**<u>ការបញ្ជាក់របស់សហព្រះរាជអាជ្ញាអំពីការផ្ញើរសារអេឡិចត្រូនិចនូវបញ្ជីឈ្មោះសាក្សីបន្ថែមសម្រាប់អង្គហេតុការប្រព្រឹត្តលើជនជាតិវៀតណាម</u>**

សហព្រះរាជអាជ្ញាបានបញ្ជាក់ថាខ្លួននឹងផ្ញើរសារអេឡិចត្រូនិចមកអង្គជំនុំជម្រះនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ

២០១៥ នូវសំណើឱ្យកោះហៅសាក្សីសម្រាប់អង្គហេតុការប្រព្រឹត្តលើជនជាតិវៀតណាម។

កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/4989 | | 00556211-00556219; 00891032-00891034; 00891035-00891037 | Civil Party Application of [REDACTED] | P | 00556218 | 00891034 | 00891036 |
| E3/4732 | | 00905169-00905174; 00427376-00427380; 00950248-00950251 | Victim Statement of Nguyen Thi Tyet | P | 00905173 | 00427379 | 00950250 |
| E3/9673 | E319/23.3.48 | 00955566-00955573; 00977843-00977849; 01032417-01032422 | Written Record of Interview of [REDACTED] | C | 00955567 | 00977844 | 01032418 |
| E3/928<br><br>E3/929 | | 00017026-00017026; 00183357-00183357; 00611668-00611668<br><br>00143507-00143508; 00143505-00143506; | Confidential telephone message on 1/4/78: Report about Total number of arrested and fired Vietnamese enemy and Written Record of Interview of Kaing Guek-Eav alias Duch | P | 00017026<br><br>00143505 | 00183357<br><br>00143507 | 00611668<br><br>N/A |
| E3/9674 | E319/23.3.44 | 00955478-00955490; 00977526-00977537; | Written Record of Interview of [REDACTED] | C | 00955486;00955487; 00955488; 00955489 | 00977534; 00977535; 00977536 | 00976203; 00976204 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00976195-00976206 | | | | | |
| E3/9675 | E319/23.3.46 | 00955532-00955541; 00977710-00977718; 01104060-01104067 | Written Record of Interview of [REDACTED] | C | 00955536-00955537; 00955488; 00955486 | 00977714; 00977535; 00977534 | 01104063-01104064; 00976204; 00976203 |
| E3/9092 | E305/13.23.382 | 00955491-00955518; 00978564-00978583; 00980432-00980452 | Statement of [REDACTED]( DC-Cam) | C | 00955507-00955508 | 00978576 | 00980444 |
| E3/9676 | E319/23.3.44.3 | 00955477-00955477; 00143507-00143508; 00611668-00611668 | Confidential telephone message on 1/4/78: Report about Total number of arrested and fired Vietnamese enemy | C | 00955477 | 00143507-00143508 | 00611668 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E1/58.1 | | 00796557-00796632; 00798164-00798256; 00798063-00798163 | Transcript of hearing on the substance in Case 002 – 03 April 2012 | P | 00796575 | 00798185 | 00798085 |

<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១២)

- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦។ (១៤.៤២)

| **<u>កាលវេលាសវនាការបន្ត</u>** |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

ជា ស៊ីទហ៊ំ... E... CAMPOS SANCHEZ